សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពាក្យខ្មែរមួយបទពោលថា
## ចង្អៀតផ្ទះចង្អៀតចុះ កុំឲ្យតែចង្អៀតចិត្ត ។

www.hoksavann.org

ថ្ងៃទី២ ឧសភា ២០១២



ពាក្យថា «ចង្អៀតផ្ទះចង្អៀតចុះ» បានសេចក្ដីថា ផ្ទះមានទំហំតូច តែមានសមាជិកគ្រួសារច្រើន ។ ទោះបីផ្ទះមានទំហំតូច ប៉ុន្ដែសមាជិកគ្រួសារ ជីដូនជីតា មាតាបិតា បងប្អូនកូនចៅ មានចិត្តគំនិតនិស្ស័យវាសនាត្រូវគ្នា គោរពសិទ្ធិគ្នាទៅវិញទៅមក តាមឋានៈខ្លួនជាមាតាបិតាជាបុត្រធីតាប្រុសស្រីជាដើម អាចប្រជ្រៀតនៅជាមួយគ្នាបាន ។ ផ្ទុយទៅវិញ មិនថាផ្ទះតូចចង្អៀតទេ សូម្បីផ្ទះមានទំហំធំទូលំទូលាយយ៉ាងណាក៏ដោយ បើចិត្តគំនិតអធ្យាស្រ័យធាតុពុំត្រូវគ្នាហើយ ពុំអាចរស់នៅជាមួយគ្នាបានឡើយ ។ ដូចពាក្យខ្មែរមួយឃ្លាទៀតខាងលើនេះថា «កុំឲ្យតែចង្អៀតចិត្ត» គឺបើមានចិត្តគំនិតពុំត្រូវគ្នា ឈ្មោះថាចង្អៀតចិត្ត ពុំអាចរស់នៅជាមួយគ្នាបានឡើយ គឺនៅរួមតែកាយ ប៉ុន្ដែឆ្ងាយចិត្ត ។ ពាក្យខ្មែរថា បើនៅជាមួយគ្នា តែមានចិត្តផ្សេងគ្នា ថ្ងៃណាមួយអាចបែកគ្នា ។

មិនចំពោះតែក្រុមគ្រួសារទេ ក្រសួងរាជការ សមាគម អង្គការឯកជនគ្រប់បែបយ៉ាង បើមិនគោរពច្បាប់ រំលោភលើសិទ្ធិគ្នា នឹងបែកបាក់គ្នា ដោយខ្លះលាឈប់ ខ្លះត្រូវគេដេញចេញពីតំណែង និងខ្លះត្រូវដាក់ទោសទណ្ឌកម្មតាមកំហុសរបស់ខ្លួន ។ តាមសង្គមសាស្ត្រ បុគ្គលមួយរូបៗ បើចូលរួមក្នុងសង្គម មានលក្ខណៈពីរប្រភេទ គឺរូបវន្តបុគ្គល បានដល់បុគ្គផ្ទាល់ខ្លួន បំពេញកិច្ចការអ្វីតាមបំណងនិងជំនឿរបស់ខ្លួន និងនីតិបុគ្គលបានដល់មុខងាររបស់ខ្លួន ដែលច្បាប់តម្រូវឲ្យ ។ បុគ្គលដែល ជានីតិបុគ្គលមិនត្រូវយកមុខងាររបស់ខ្លួន ទៅប្រើដើម្បីប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។

ស្របតាមពាក្យខ្មែរក្នុងប្រធានបទនេះ មានទស្សនៈមួយទៀតពោលថា បុគ្គលបើនៅឆ្ងាយពីគ្នា ប៉ុន្ដែមានចិត្តមានទស្សនៈត្រូវគ្នា ថ្ងៃណាមួយអាចកាត់មកជួបគ្នា គឺការកាត់មកជួបគ្នាដោយសារចិត្តត្រូវគ្នា ។ ប៉ុន្ដែមានពាក្យខ្មែរមួយសម្រួលថា ចានក្នុងរាវរែងអីរណ្ដំគ្នា បានសេចក្ដីថា នៅជាមួយគ្នាលែងអីនឹងទាស់គ្នាខ្លះ ដូច្នេះត្រូវលេបថ្នលេបគ្រួសខ្លះទៅ បានសេចក្ដីថាត្រូវចេះអត់ឱនឲ្យដល់គ្នាទៅវិញទៅមក ប៉ុន្ដែមានពាក្យជ្រៀតសួរថា បើលេបថ្នលេបគ្រួសតែម្ដងអាចអត់ទ្រាំបាន ចុះបើទាស់គ្នារាល់ថៃ ត្រូវអត់ធន់រាល់ថ្ងៃ គឺលេបថ្នលេបគ្រួសរាល់ថ្ងៃ តើអាចលេបបានរាល់ថ្ងៃឬទេ ?

តាមព្រះពុទ្ធសាសនា វិធីដំណោះស្រាយតាមយថាហេតុ បើរឿងហេតុល្មមៗអាចសំរួលគ្នាបាន ក៏ចេះតែសំរួលគ្នា រស់នៅជាមួយគ្នាតទៅទៀត បើសំរួលគ្នាលែងកើតហើយ ទោះបីឲ្យចាស់ទុំជួយសំរួលក៏ពុំស្រុះស្រួលគ្នា ដូច្នេះវិធីជំរើសមានតែម៉្យាងគឺចែកផ្លូវគ្នាដើរ គឺលែងលះគ្នា បើប្ដីប្រពន្ធ ដើម្បីកុំឲ្យខូចផ្លូវចិត្ត រហូតដល់ថ្នាក់ធ្វើអត្តឃាតខ្លួនឯង ។ ចំពោះរឿងនេះ បើប្រទេសនៅអឺរ៉ុប នៅអាមេរិក ប្ដីនិងប្រពន្ធ បើអស់ចិត្តលែងនៅជាមួយគ្នាបានហើយ គេសុំលែងគ្នាតែម្ដង ហើយគេនៅតែរាប់អានគ្នាដូចធម្មតា ពុំចងកំហឹងនឹងគ្នាឡើយ ។ ដូចគ្នានេះដែរ ពេលគេប្រជុំគ្នាក្នុងរដ្ឋសភា ព្រឹទ្ធសភា គេជជែកគ្នាបញ្ចេញយោបល់អំពីមធ្យោបាយឲ្យសង្គមរីកចំរើន ប៉ះទង្គិចគ្នាយ៉ាងតឹងសរសៃក តែដល់ពេលចេញពីអង្គប្រជុំ គេនៅរាប់អានគ្នាជាធម្មតា ពុំចងគំនុំគ្នាឡើយ ។ បើខ្មែរធ្វើបានដូចលក្ខណៈគេនេះជាការប្រពៃណាស់ ជាពិសេសគណបក្សកាន់អំណាចនិងគណបក្សប្រឆាំង ។

ពាក្យថា «ចង្អៀតផ្ទះចង្អៀតចុះ កុំឲ្យតែចង្អៀតចិត្ត» នេះ ជាពាក្យបញ្ជាក់អំពីការរស់នៅជាមួយគ្នាក្នុងសង្គម ចាប់ពីពីរនាក់ឡើងទៅហៅថាសង្គម ជាសង្គមគ្រួសារក្ដី សង្គមប្រទេសជាតិទាំងមូលក្ដី ។ មនុស្សទាំងអស់ត្រូវស្ថិតនៅក្រោមអំណាចច្បាប់សង្គម ទើបរស់នៅជាមួយគ្នាបាន ដោយគោរពតាមច្បាប់ទម្លាប់ដែលរដ្ឋបានចែង ។ តាមទំនៀមទំលាប់ខ្មែរ ពេលទាស់ទែងខ្វែងគំនិតគ្នាក្នុងក្រុមគ្រួសារ ឬអ្នកភូមិមានទំនាស់គ្នា តែងឲ្យចាស់ព្រឹទ្ធាចារ្យ ឬប្រគេនព្រះសង្ឃជួយដោះស្រាយ ។ បើទំនាស់ខ្លាំងមិនអាចដោះស្រាយបាន ទើបប្ដឹងទៅតុលាការ ។ ចំពោះដំណោះស្រាយរបស់ព្រឹទ្ធាចារ្យឬព្រះសង្ឃ គឺវិធីសំរបសំរួលតាមធម៌អាចស្របតាមភស្តុតាងជាក់ស្ដែង ។៚

*    *

*